ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :.........៤៣៥.........ក.ប/ប្រ.ក.ម.៣

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់នឹងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨
- តាមការចាំបាច់របស់ក្រសួង

## សម្រេច

### ប្រការ១.-

ប្រកាសនេះមានគោលបំណងកំណត់អំពីលក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ប្រការ២**.-

សម្រាប់គោលដៅនៃប្រកាសនេះ ៖

(ក) ពាក្យថា **ការងារផ្ទះ** សំដៅយកកិច្ចការទាំងឡាយដែលត្រូវប្រតិបត្តិនៅក្នុងរង្វង់គ្រួសារមួយ ឬសម្រាប់គ្រួសារមួយជាកំណត់ដូចជាការបោសសំអាត ការចំអិនអាហារ ការបោកគក់ និងអ៊ុត ការថែទាំកុមារ ការថែទាំមនុស្សចាស់ ការថែទាំសមាជិកគ្រួសារ ការថែទាំសួន ការថែទាំទ្រព្យសម្បត្តិ ការបើកបររថយន្តសម្រាប់គ្រួសារ និងការថែទាំសត្វចិញ្ចឹមក្នុងគ្រួសារជាដើម។

(ខ) ពាក្យថា **កម្មករការងារផ្ទះ** សំដៅយកជនណាដែលទទួលធ្វើកិច្ចការណាមួយ ឬលើសពីមួយនៃការងារផ្ទះដោយស្ម័គ្រចិត្ត និងទទួលកម្រៃ។

(គ) ជនណាម្នាក់គ្រាន់តែទទួលធ្វើកិច្ចការណាមួយ ឬលើសពីមួយនៃការងារផ្ទះម្តងម្កាល ឬ មិនទៀងទាត់ និងមិនឈរលើមូលដ្ឋាននៃវិជ្ជាជីវៈណាមួយ មិនមែនជាកម្មករការងារផ្ទះទេ។

**ប្រការ៣**.-

ប្រកាសនេះអនុវត្តចំពោះកម្មករការងារផ្ទះទាំងអស់។

ប្រកាសនេះមិនអនុវត្តទេចំពោះជនណាដែលត្រូវបានគ្រួសារណាមួយទទួលយកមកឱ្យរស់នៅជាមួយ ហើយត្រូវបានគ្រួសារនេះចាត់ចែងឱ្យជួយធ្វើការងារក្នុងផ្ទះ ដោយទទួលបានសិទ្ធិ ប្រព្រឹត្តិកម្ម ការការពារ និង ផលប្រយោជន៍ដូចគ្នានឹងសមាជិកនីមួយៗនៃគ្រួសារ។

**ប្រការ៤**.-

កម្មករការងារផ្ទះត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើង។ ក្មេងអាយុចាប់ពី១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំ អាចអនុញ្ញាតឱ្យធ្វើការងារផ្ទះណាដែលស្រាលៗ មិនមានលក្ខណៈងាយបង្កឱ្យមានគ្រោះថ្នាក់ ឬ ប៉ះពាល់សុខភាព។

**ប្រការ៥**.-

កិច្ចការទាំងឡាយ ដែលត្រូវចាត់ឱ្យកម្មករការងារផ្ទះទទួលធ្វើ ត្រូវតែកំណត់ឱ្យបានច្បាស់នៅក្នុងកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ។

**ប្រការ៦**.-

ក្នុងករណីកម្មករការងារផ្ទះស្នាក់នៅជាមួយគ្រួសារណាមួយ ដែលជាទីកន្លែងធ្វើការងាររបស់ខ្លួន និយោជកត្រូវផ្តល់ឱ្យកម្មករការងារផ្ទះដោយមិនគិតកម្រៃនូវការហូបចុក ការស្នាក់នៅសមរម្យ និងការពិនិត្យព្យាបាលបឋមនៅពេលមានជំងឺ។

**ប្រការ៧**.-

កម្មករការងារផ្ទះ និងនិយោជកនីមួយៗ ត្រូវធ្វើកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ

ឱ្យបានស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់ និងបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

កិច្ចសន្យាការងាររវាងកម្មករការងារផ្ទះ និងនិយោជក ត្រូវកំណត់ឱ្យបានច្បាស់អំពីលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

-ឈ្មោះ និងអាសយដ្ឋាន របស់និយោជក និងកម្មករការងារផ្ទះ។

-អាសយដ្ឋាននៃកន្លែងធ្វើការងារ។

-កាលបរិច្ឆេទចាប់ផ្តើម។

-ប្រភេទការងារដែលត្រូវបំពេញ។

-ប្រាក់ឈ្នួល របៀបគិតប្រាក់ឈ្នួល និងការកំណត់អំពីការបើកប្រាក់ឈ្នួល។

-ម៉ោងធ្វើការធម្មតា។

-ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល និងការឈប់សម្រាកប្រចាំថ្ងៃ និងប្រចាំសប្តាហ៍។

-ការផ្តល់អាហារ និងកន្លែងស្នាក់នៅ (បើមាន)។

-រយៈពេលការសាកល្បងការងារ មិនលើសពីមួយខែ (បើមាន)។

-លក្ខខណ្ឌសម្រាប់ការរៀបចំឱ្យកម្មករការងារផ្ទះត្រឡប់ទៅស្រុក(ផ្ទះ)វិញ (បើមាន)។

-លក្ខខណ្ឌដែលពាក់ព័ន្ធជាមួយនឹងការបញ្ចប់កិច្ចសន្យាការងារដូចជារយៈពេលនៃការជូនដំណឹងជាមុនដោយកម្មករការងារផ្ទះ ឬនិយោជក (បើមាន)។

**ប្រការ៨**.-

និយោជកជាជនបរទេស ដែលស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានកម្មករការងារផ្ទះជាជនជាតិខ្មែរធ្វើការក្នុងគ្រួសារ ឬសម្រាប់គ្រួសាររបស់ខ្លួន ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃប្រកាសនេះ និងបទបញ្ញាពាក់ព័ន្ធនានាជាធរមាន។

**ប្រការ៩**.-

ការឈប់សម្រាកប្រចាំសប្តាហ៍ ត្រូវមានថេរវេលាអប្បបរិមា២៤ម៉ោងបន្តបន្ទាប់។ ជាគោលការណ៍ត្រូវឈប់នៅថ្ងៃអាទិត្យ លើកលែងតែមានការព្រមព្រៀងដោយស្ម័គ្រចិត្តរបស់កម្មករការងារផ្ទះ ការឈប់សម្រាកនេះអាចធ្វើឡើងនៅក្នុងថ្ងៃណាមួយក៏បាននៅក្នុងសប្តាហ៍ដដែល។

បទប្បញ្ញត្តិនៃប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល ត្រូវយកមកអនុវត្តចំពោះកម្មករការងារផ្ទះ។

កម្មករការងារផ្ទះដែលធ្វើការងារនៅថ្ងៃឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល ត្រូវទទួលបានប្រាក់ឈ្នួលស្មើនឹង២០០ (ពីររយ) ភាគរយនៃប្រាក់ឈ្នួលនៃថ្ងៃធ្វើការងារធម្មតា។

**ប្រការ១០.-**

និយោជកត្រូវបើកប្រាក់ឈ្នួលជាសាច់ប្រាក់ ជូនកម្មករការងារផ្ទះដោយផ្ទាល់ ឬតាមធនាគារដោយផ្អែកទៅលើការព្រមព្រៀងគ្នាដោយស្ម័គ្រចិត្តរវាងកម្មករការងារផ្ទះ និងនិយោជក។ ការបើកប្រាក់ឈ្នួលសម្រាប់កម្មករការងារផ្ទះសម្រាប់ខែនីមួយៗ ត្រូវធ្វើឡើងនៅថ្ងៃធ្វើការដោយត្រូវមានការជូនដំណឹងជាមុនអំពីថ្ងៃបើកប្រាក់ឈ្នួលនេះ។ ការបើកប្រាក់ឈ្នួលនេះអាចធ្វើឡើងរៀងរាល់១៥ថ្ងៃម្តង ក្នុងករណីមានការស្នើសុំពីកម្មករការងារផ្ទះ ឬមានចែងនៅក្នុងកិច្ចសន្យាការងារ។

**ប្រការ១១.-**

រាល់វិវាទការងារដែលបានកើតឡើងរវាងកម្មករការងារផ្ទះជាមួយនឹងនិយោជក ភាគីទាំងពីរនៃវិវាទត្រូវតែយកចិត្តទុកដាក់ដោះស្រាយឱ្យអស់លទ្ធភាពដោយមធ្យោបាយសន្តិវិធី។ ក្នុងករណីមិនសះជា ភាគីណាមួយនៃវិវាទអាចប្តឹងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះអ្នកនៅរាជធានីភ្នំពេញ និងមកមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះអ្នកនៅខេត្ត។

ការដោះស្រាយវិវាទការងាររវាងកម្មករការងារផ្ទះ និងនិយោជក ត្រូវតែធ្វើឡើងដោយអនុលោមតាមកិច្ចសន្យាការងារដែលបានចុះហត្ថលេខារវាងគូភាគី បទប្បញ្ញត្តិទាក់ទងនឹងការងារ និងបទបញ្ញាផ្សេងៗជាធរមាន។

ក្នុងករណីវិវាទការងារនេះនៅតែមិនសះជា ភាគីណាមួយនៃវិវាទអាចប្តឹងទៅតុលាការ។

**ប្រការ១២.-**

រាល់ការងារផ្ទះ ដែលមានលក្ខណៈជាការងារដោយបង្ខំឬជាកាតព្វកិច្ច ការងារកាត់ជំពាក់ការងារមានលក្ខណៈជាទម្រង់ធ្ងន់ធ្ងរ និងបែបទាសភាព ត្រូវបានហាមឃាត់។

**ប្រការ១៣.-**

និយោជក ត្រូវទទួលខុសត្រូវលើគ្រោះថ្នាក់ការងារទាំងអស់លើកម្មករការងារផ្ទះ និងរបបសន្តិសុខសង្គម ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធ នៃព្រះរាជាណាចក្រកម្ពុជា ដូចកម្មករនិយោជិតផ្សេងៗទៀតដែរ។

**ប្រការ១៤.-**

អ្នកប្រព្រឹត្តិល្មើសទៅនឹងប្រកាសនេះ ត្រូវទទួលការផាកពិន័យ ឬផ្តន្ទាទោសដូចមានចែងក្នុងច្បាប់ និងបទបញ្ញាជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន អង្គភាពក្រោមចំណុះក្រសួង និង ទីភ្នាក់ងារជាតិមុខរបរ និងការងារ ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ១៥កើត ខែ ជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

***កន្លែងទទួល៖***

*-ទីស្តីការគណៈរដ្ឋមន្ត្រី*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ*

*-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ*

*-ដូចប្រការ១៥*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*